# GC ពហុគាំពារ



# តើអ្វីទៅជា GC ពហុគាំពារ?

GC ពហុគាំពារ គឺជាគម្រោងធានារ៉ាប់រងមានកាលកំណត់រយៈពេល ៥ឆ្នាំ ដែលផ្តល់ការការពារខ្ពស់លើគ្រោះថ្នាក់ជាយថាហេតុរហូតដល់ 400% នៃទឹកប្រាក់ត្រូវបានធានាជាមួយនឹងបុព្វលាភដែលមានតម្លៃសមរម្យ។

# លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | ចាប់ពី 15 ដល់ 60ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 5ឆ្នាំ |
| រយៈពេលបង់បុព្វលាភ | ការបង់ម្តងផ្តាច់, 2ឆ្នាំ ឬ3ឆ្នាំ |
| វិធីសាស្ត្របង់បុព្វលាភ | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ឬប្រចាំខែ (លើកលែងចំពោះការបង់ម្តងផ្តាច់) |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $10,000 ឡើង |

# អត្ថប្រយោជន៍ធានារ៉ាប់រង

សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍
**100%** នៃទឹកប្រាក់ត្រូវបានធានា

សំណងមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ
**200%** នៃទឹកប្រាក់ត្រូវបានធានា

សំណងមរណភាពដោយគ្រោះថ្នាក់ជាយថាហេតុ នៅពេលកំពុងធ្វើដំណើរដោយប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ
**300%** នៃទឹកប្រាក់ត្រូវបានធានា

សំណងមរណភាពដោយគ្រោះថ្នាក់ជាយថាហេតុ នៅពេលកំពុងធ្វើដំណើរដោយប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈក្នុងអំឡុងពេលថ្ងៃឈប់សម្រាកបុណ្យជាតិ*
**400%** នៃទឹកប្រាក់ត្រូវបានធានា។

*ថ្ងៃឈប់សម្រាកបុណ្យជាតិគឺ ពិធីបុណ្យភ្ជុំបិណ្ឌ ព្រះរាជពិធីបុណ្យអុំទូក និងពិធីបុណ្យចូលឆ្នាំខ្មែរ។

## ករណីមិនធានាសំខាន់ៗ

**១. មរណភាព**
(១) ការធ្វើអត្តឃាតក្នុងរយៈពេល ២ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ។
(២) ការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។
(៣) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) ដែលរួមមានទាំងជំងឺអេដស៍ និង/ឬការបំលែង ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។
(៤) ការប្រើប្រាស់ថ្នាំញៀន ឬថ្នាំភ្លេចអារម្មណ៍ ឬការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬរោគសញ្ញាផ្សេងៗដូចដែលបានកំណត់ដោយច្បាប់ដែលបានចូលជាធរមាន។

**២. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**
(១) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាពប្រឆាំងនឹងរដ្ឋាភិបាលនិងអំពើភេរវកម្ម។
(២) ការធ្វើដំណើរចូល ការចាកចេញ ការប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរបង់ប្រាក់ធម្មតា ឬអ្នកបម្រើការលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ពាណិជ្ជមួយ ដែលធ្វើការជាប្រចាំ និងទៀងទាត់តាមកាលវិភាគ និងគន្លងធ្វើដំណើរផ្លូវអាកាសដែលបានកំណត់របស់ក្រុមហ៊ុន។
(៣) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងមានសុពលភាព ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលអ្នកត្រូវបានធានារ៉ាប់រងបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។
(៤) ការចូលរួមក្នុងសកម្មភាពកីឡាគ្រោះថ្នាក់រួមមាន តែមិនកំណត់ត្រឹមការជ្រមុជទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងល្បឿនលឿនណាមួយ ឬសកម្មភាពកីឡាអាជីព។

**៣. មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ**
(១) អ្នកត្រូវបានធានារ៉ាប់រងបានដឹងអំពីបញ្ហារាងកាយថាមានជំងឺ ឬឈឺមុនពេលចាប់ផ្តើមកិច្ចសន្យាធានារ៉ាប់រង ប៉ុន្តែអ្នកត្រូវបានធានារ៉ាប់រងមិនបានជូនដំណឹងដល់ក្រុមហ៊ុនឡើយ។
(២) អ្នកត្រូវបានធានារ៉ាប់រងស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណចុះបញ្ជីត្រឹមត្រូវ។
(៣) ការមានគភ៌ ការសម្រាលកូន ការរលូតកូន ឬផលវិបាកណាមួយកើតចេញពីកត្តាទាំងអស់នេះ។

ករណីមិនធានាទាំងនេះ គឺជាចំនុចសំខាន់ខ្លះៗប៉ុណ្ណោះ។ សម្រាប់ករណីមិនធានាលម្អិតទាំងស្រុង សូមពិនិត្យមើល ខ និងលក្ខខណ្ឌធានារ៉ាប់រង។

ចំណាំ៖ ខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិត សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។ ក្នុងករណីដែលកើតមានភាពមិនស៊ីចង្វាក់គ្នា ត្រូវយក ខ និងលក្ខខណ្ឌធានារ៉ាប់រងជាគោល។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ


023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

អគារ C ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ